**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ :  ២៤/២០០៧ កបធ.សសរ

## វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨

## សម្រេច

**ប្រការមួយ.-**

ប្រការ ៦ ប្រការ ១២ ប្រការ ១៣ ប្រការ ១៨ ប្រការ ២៦ និង ប្រការ ២៩ នៃបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៨ និង ប្រការ ៩ ( កែប្រែ ) នៃវិសោធនកម្មបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ១៩៩៨ ត្រូវបានធ្វើវិសោធនកម្ម ដូចខាងក្រោម :

**ប្រការ ៦ ថ្មី**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលមានបំណងសុំឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ ឬ ជាបេក្ខជនសមាជិក ព្រឹទ្ធសភា ត្រូវសុំច្បាប់ ឈប់ពិសេស ៧ ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត ។ ការសុំនេះ ត្រូវបានការអនុញ្ញាត ។

**ប្រការ ៩ ថ្មី ( ពីរ )**

មន្ត្រីរាជការអគ្គលេខាធិការដ្ឋាន ត្រូវបំពេញការងារស្របតាមច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និង ត្រូវបានឈប់ សម្រាកការងារប្រចាំឆ្នាំតាមការកំណត់របស់រដ្ឋ លើកលែងតែក្នុងករណីចាំបាច់ដែលមានកំណត់នៅក្នុង ច្បាប់ដោយឡែក ។

**ប្រការ ១២ ថ្មី**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវកោះអញ្ជើញដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ ដោយសមាជិកដែលមាន អាយុច្រើនជាងគេដែលមានវត្តមាន បើប្រធានមានធុរៈមិនអាចធ្វើបាន ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញអាចចាត់ទុកជាបានការ លុះត្រាតែមានសមាជិកលើសពីពាក់កណ្ដាលចូលរួមប្រជុំ ។

អាសនានុក្រមសមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំតាមលំដាប់អតីតភាព ។ ក្នុងករណីមានអតីតភាពស្មើគ្នា អាសនានុក្រមត្រូវរៀបចំតាមលំដាប់អាយុ ។

**ប្រការ ១៣ ថ្មី**

ការកោះប្រជុំត្រូវធ្វើជាលិខិតអញ្ជើញភ្ជាប់ជាមួយគម្រោងរបៀបវារៈ ហើយផ្ញើជូនសមាជិកយ៉ាងតិច ២ ថ្ងៃមុនថ្ងៃ កំណត់ប្រជុំ លើកលែងក្នុងការប្រញាប់ ។

សមាសភាពគណៈលេខាធិការនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាធម្មនុញ្ញ រួមមានអគ្គលេខាធិការ ឬ អគ្គលេខាធិការរង និងលេខាធិការពីរនាក់ ឬ មួយចំនួនតាមការចាំបាច់ ។

នៅក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថាត្រូវប្រជុំសម្ងាត់ មុននឹងបើកកិច្ចប្រជុំនេះ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវចាត់ឱ្យគណៈលេខាធិការពិនិត្យ និង រាយការណ៍ថា គ្មានមនុស្សដទៃនៅក្នុងសាលប្រជុំទេ ។

**ប្រការ ១៨ ថ្មី**

ការអនុម័តទាំងឡាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ( ៥ សម្លេងយ៉ាងតិច) លើកលែងតែការសម្រេចដកសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលត្រូវអនុម័តតាមមតិភាគច្រើនពីរភាគបី ( ៦ សម្លេងយ៉ាងតិច ) ។

**ប្រការ ២៦ ថ្មី**

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញដែលត្រូវទទួលវិន័យតាមប្រការ ២៣ ប្រការ ២៤ ប្រការ ២៥ នៃបទបញ្ជាផ្ទៃក្នុងនេះ ក្រោយពីបានទទួលដំណឹងពីសំណុំរឿងផ្ទាល់ខ្លួន ត្រូវធ្វើការដោះសាក្នុងរយៈពេល៥ថ្ងៃ ។ ផុតកំណត់នេះ ទោះបីសាមីខ្លួន បានធ្វើការដោះសា ឬ មិនដោះសាក្តី ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចដាក់វិន័យតាមមតិភាគច្រើន ដូចមានចែងក្នុងប្រការ ១៨ ថ្មី និង ប្រការ ១៩ នៃបទបញ្ជា ផ្ទៃក្នុងនេះ ។

**ប្រការ ២៩ថ្មី**

បទបញ្ជាផ្ទៃក្នុងនេះនឹងអាចកែប្រែបាន លុះត្រាតែមានសេចក្តីស្នើសុំ ពីសមាជិក ចំនួន ៣នាក់ ឡើងទៅ ហើយត្រូវបានអនុម័តយល់ព្រមដោយមតិភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។

**ប្រការពីរ.-**

វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនេះ ត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញអនុម័តកាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៧ ខែ សីហា ឆ្នាំ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "
- កាលប្បវត្តិ - ឯកសារ